អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

# កិច្ចប្រជុំពេញអង្គរបស់ចៅក្រមនៃ អ.វ.ត.ក

ថ្ងៃទី២ ដល់ថ្ងៃទី៦ ខែមិនា ២០០៩

## សេចក្តីប្រកាសព័ត៌មានរបស់អង្គភាពគាំពារការការពារក្តី

**១.** អង្គភាពគាំពារការការពារក្តី (DSS) សូមសម្តែងនូវការសាទរចំពោះចៅក្រមដែលបានអនុម័តលើការធ្វើវិសោធនកម្មសំខាន់ៗមួយចំនួននៅឯកិច្ចប្រជុំពេញអង្គនៅសប្តាហ៍នេះ។ ទាំងចៅក្រមកម្ពុជា និងចៅក្រមអន្តរជាតិ បានបង្ហាញការប្តេជ្ញាចិត្តច្បាស់លាស់ ដើម្បីធានាថា អ.វ.ត.ក ដំណើរការយ៉ាងត្រឹមត្រូវ និង ដ៏មានប្រសិទ្ធិភាព ។ ជាពិសេស ចៅក្រមបានថ្លឹងថ្លែងយ៉ាងប្រុងប្រយ័ត្ននូវបំណងប្រាថ្នា ដើម្បីផ្តល់ឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីមានសម្លេងនៅក្នុងដំណើរការនីតិវិធីជាមួយសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ។

**២.** អង្គភាពគាំពារការការពារក្តីសូមស្វាគមន៍នូវសេចក្តីថ្លែងការណ៍ដោយចៅក្រមអន្តរជាតិ ដែលបានបញ្ជាក់អំពីកង្វល់របស់ពួកគេ ចំពោះការចោទប្រកាន់ពីអំពើពុករលួយនៅក្នុង អ.វ.ត.ក ដែលមិនទាន់បានដោះស្រាយនៅឡើយ ។ ចំនុចនេះបានបញ្ជាក់ឡើងវិញនូវជំហររបស់ពួកគេនៅឯកិច្ចប្រជុំពេញអង្គថា ការចោទប្រកាន់អំពីការបង់ប្រាក់ដើម្បីទទួលបានមុខតំណែង ត្រូវតែបានដោះស្រាយ “ឲ្យបានពេញលេញ និង ត្រឹមត្រូវ [...] និង ប្រកបដោយតម្លាភាព” ហើយជួយសំរាលអ្នកដែលមានការព្រួយបារម្ភអំពីការចាត់ចែងយុត្តិធម៌នៅក្នុង អ.វ.ត.ក ថា អាចទទួលរងគ្រោះដោយសម្បទាននយោបាយ ។

ធ្វើនៅថ្ងៃទី ៦ ខែមិនា ឆ្នាំ២០០៩

**Richard J Rogers**

**អង្គភាពគាំពារការការពារក្តី**

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh